# ទីភ្នាក់ងារការពារបរិស្ថាន (Environmental Protection Agency, EPA)របស់Philanthropy Northwest
# ជំនួយលើកស្ទួយសហគមន៍យុត្តិធម៌បរិស្ថាន Region 10

## សំណើសុំការដាក់ពាក្យសុំ

**ចំណងជើងនៃការដាក់ពាក្យសុំ៖**ជំនួយលើកស្ទួយសហគមន៍យុត្តិធម៌បរិស្ថាន Region 10របស់ EPA

**ចំនួនមូលនិធិសរុប៖** $40 លាន

**ចំនួនមូលនិធិប៉ាន់ស្មានក្នុងមួយគម្រោង៖**$150,000-$350,000

- ប្រភេទទី 1 (ការវាយតម្លៃ)៖រហូតដល់ $150,000
- ប្រភេទទី 2 (ការធ្វើផែនការ)៖រហូតដល់ $250,000
- ប្រភេទទី 3 (អភិវឌ្ឍ)៖រហូតដល់ $350,000

*សម្រាប់ព័ត៌មានលម្អិតអំពីប្រភេទមូលនិធិជំនួយនីមួយៗសូមមើលព័ត៌មានខាងក្រោម។*

**រយៈពេលរំពឹងទុកនៃការអនុវត្ត៖**ជំនួយ 1- ឬ 2-ឆ្នាំពីខែឧសភាឆ្នាំ 2025 ដល់ខែមិថុនាឆ្នាំ2027

ការផ្ដល់មូលនិធិនេះគឺបើកចំហសម្រាប់អង្គការដែលមានសិទ្ធិនៅក្នុងតំបន់ជនបទនិងទីក្រុងនៅទូទាំង Region 10 របស់EPA ដែលរួមមានរដ្ឋ Alaska, Idaho, Oregon, Washingtonនិង 271 Tribal Nations។**<u>បច្ចុប្បន្នយើងកំពុងទទួលយកការដាក់ពាក្យសុំសម្រាប់ជំនួយប្រភេទទី 3ប៉ុណ្ណោះ។</u>**

| ថ្ងៃផុតកំណត់សំខាន់ៗ (ជុំទីមួយ) * | ថិរវេលា |
|---|---|
| ជុំទីមួយការដាក់ពាក្យសុំប្រភេទទី3បើក | ថ្ងៃទី8ខែតុលាឆ្នាំ2024 |
| សិក្ខាសាលាព័ត៌មាន | ខែតុលាឆ្នាំ 2024 |
| ជុំទីមួយកាលបរិច្ឆេទកំណត់ការដាក់ពាក្យសុំប្រភេទទី 3 | ថ្ងៃទី 15ខែធ្នូឆ្នាំ2024វេលាម៉ោង11:59ល្ងាចម៉ោងនៅតំបន់ប៉ាស៊ីហ្វិក |
| ការប៉ាន់ស្មានពេលវេលាពិនិត្យពាក្យផ្ទៃក្នុង | ថ្ងៃទី10ខែមករា - ថ្ងៃទី28ខែកុម្ភៈឆ្នាំ 2025 |
| ការប៉ាន់ស្មានពេលវេលាជូនដំណឹងអំពីការជ្រើសរើស | ខែមីនាឆ្នាំ 2025 |
| ការប៉ាន់ស្មានពេលវេលាចុះហត្ថលេខាលើកិច្ចព្រមព្រៀង/កាលបរិច្ឆេទចាប់ផ្ដើម | ខែឧសភាឆ្នាំ 2025 |
| កាលបរិច្ឆេទបញ្ចប់នៃរយៈពេលផ្ដល់មូលនិធិ | ខែឧសភាឆ្នាំ2027 (ជំនួយរយៈពេល 2 ឆ្នាំ) |

** ចំណាំថាកាលបរិច្ឆេទកំណត់សំខាន់ៗទាំងនេះគឺសម្រាប់ជំនួយជុំទីមួយ (ប្រភេទទី3) ប៉ុណ្ណោះ។សម្រាប់កាលបរិច្ឆេទផុតកំណត់ប្រភេទ1 និង2 សូមមើលតារាងពេលវេលានៅក្នុងតារាងខាងក្រោម។*

**តំណការដាក់ពាក្យសុំ៖** https://philanthropynorthwest.fluxx.io/user_sessions/new
**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖**thrivingcommunities@philanthropynw.org

ពាក្យនេះបានបកប្រែជាប្រាំបីភាសាផ្សេងគ្នា។សម្រាប់ការបកប្រែពាក្យនេះជាភាសាខាងក្រោមសូមចុចតំណភ្ជាប់ខាងក្រោម៖

- កម្ពុជាខ្មែរ
- ចិន
- កូរ៉េ
- ឡាវ

- រុស្ស៊ី
- សូម៉ាលី
- អេស្ប៉ាញ
- វៀតណាម

សម្រាប់ការដាក់ពាក្យសុំជុំទីមួយដែលផុតកំណត់នៅថ្ងៃទី15ខែធ្នូឆ្នាំ2024 Philanthropy Northwest**កំពុងទទួលយកតែពាក្យសុំប្រភេទ3**សម្រាប់ការអភិវឌ្ឍ/ការអនុវត្តគម្រោងប៉ុណ្ណោះ។តារាងពេលវេលាសម្រាប់កម្មវិធីផ្តល់ជំនួយទាំងមូលមានដូចខាងក្រោម៖

| ជុំ | បើកទទួលពាក្យសុំ | ថ្ងៃផុតកំណត់ដាក់ពាក្យសុំ* | ប្រភេទទី1 | ប្រភេទទី2 | ប្រភេទទី3 | សេចក្តីជូនដំណឹងស្តីពីការជ្រើសរើស |
|---|---|---|---|---|---|---|
| 1 | ថ្ងៃទី8ខែតុលាឆ្នាំ2024 | ថ្ងៃទី15ខែធ្នូឆ្នាំ2024 | | | X | ខែមីនាឆ្នាំ2025 |
| 2 | ខែមករាឆ្នាំ 2025 | ខែមេសាឆ្នាំ2025 | X | X | X | ខែមិថុនាឆ្នាំ 2025 |
| 3 | ខែមីនាឆ្នាំ 2025 | ខែឧសភាឆ្នាំ2025 | X | X | X | ខែកក្កដាឆ្នាំ 2025 |
| 4 | ខែឧសភាឆ្នាំ2025 | ខែកក្កដាឆ្នាំ2025 | X | X | | ខែកញ្ញាឆ្នាំ 2025 |
| 5 | ខែសីហាឆ្នាំ2025 | ខែតុលាឆ្នាំ2025 | X | X | | ខែធ្នូឆ្នាំ 2025 |
| 6 | ខែវិច្ឆិកាឆ្នាំ 2025 | ខែកុម្ភៈឆ្នាំ2026 | X | X | | ខែមេសាឆ្នាំ2026 |
| 7 | ខែកុម្ភៈឆ្នាំ 2026 | ខែមេសាឆ្នាំ2026 | X | | | ខែមិថុនាឆ្នាំ2026 |

* យើងបើកទទួលពាក្យសុំគ្រប់ពេលអំឡុងពេលបើកទទួលពាក្យសុំនៃប្រភេទជំនួយជាក់លាក់ (ដែលសម្គាល់ដោយ "X")។ចំណាំថាក្រឡោន "កាលបរិច្ឆេទដាក់ពាក្យសុំ" ត្រូវគ្នានឹងក្រឡោន "សេចក្តីជូនដំណឹងស្តីពីការជ្រើសរើស"។ឧទាហរណ៍ពាក្យស្នើសុំប្រភេទទី 3ទាំងអស់ដែលទទួលបានត្រឹមថ្ងៃទី15 ខែធ្នូឆ្នាំ2024 នឹងត្រូវបានពិនិត្យឡើងវិញសម្រាប់ការជូនដំណឹងអំពីការជ្រើសរើសនៅខែមីនាឆ្នាំ 2025ដែលមានសក្តានុពលប្រសិនបើត្រូវបានអនុម័ត។ពាក្យទាំងឡាយណាដែលទទួលបានក្រោយថ្ងៃទី15 ខែធ្នូឆ្នាំ 2024 នឹងត្រូវបានពិនិត្យនៅជុំបន្ទាប់ដោយមានកាលបរិច្ឆេទផ្តល់មូលនិធិគម្រោងដែលអាចកើតមាននៅខែមិថុនាឆ្នាំ 2025 ។

**តារាងមាតិកា៖**


| ផ្នែក | ចំណងជើងផ្នែក | ទំព័រ |
|---|---|---|
| | 1. សាវតារ | 2 |
| | 2. គោលបំណង | |
| | 3. សិទ្ធិចូលរួមនិងលក្ខណសម្បត្តិ | |
| | 4. លក្ខខណ្ឌតម្រូវនៃការដាក់ពាក្យស្នើសុំ | |

| | | |
|---|---|---|
| | 5. ថ្លៃចំណាយដែលអាចអនុញ្ញាតនិងមិនអាចអនុញ្ញាត | |
| | 6. ទិដ្ឋភាពទូទៅនៃកម្មវិធីនិងប្រភេទនៃមូលនិធិដែលមាន<br>i. ជំនួយក្នុងការវាយតម្លៃ<br>ii. ជំនួយក្នុងការធ្វើផែនការ<br>iii. ជំនួយអភិវឌ្ឍន៍<br>iv. មូលនិធិគ្មានការប្រកួតប្រជែង | |
| | 7. កាលវិភាគកម្មវិធីជំនួយ | |
| | 8. សំណួរនិងការណែនាំអំពីការដាក់ពាក្យសុំ | |
| | 9. ដំណើរការពិនិត្យ | |
| | 10. លក្ខណៈវិនិច្ឆ័យលើការវាយតម្លៃ | |
| | 11. លក្ខខណ្ឌតម្រូវនៃការរាយការណ៍ | |
| | 12. លក្ខខណ្ឌ | |
| | 13. បញ្ជីត្រួតពិនិត្យការដាក់ពាក្យសុំ | |

## 1. សារតារ

កម្មវិធីផ្តល់ជំនួយក្នុងការលើកស្ទួយសហគមន៍យុត្តិធម៌បរិស្ថានរបស់ ទីភ្នាក់ងារការពារបរិស្ថាន (EPA)(“កម្មវិធីលើកស្ទួយសហគមន៍”)**មានគោលបំណងផ្តល់ភាពងាយស្រួលសម្រាប់អង្គការតាមសហគមន៍ក្នុងការទទួលបានមូលនិធិយុត្តិធម៌បរិស្ថានសហព័ន្ធ។**Philanthropy Northwest បានបង្កើតដំណើរការជំនួយដែលមានភាពងាយស្រួលតាមដែលអាចធ្វើទៅបានជាមួយនឹងមូលនិធិសហព័ន្ធដូច្នេះអ្នកដាក់ពាក្យសុំមិនគួរបាក់ទឹកចិត្តដោយផ្អែកលើប្រភពនៃមូលនិធិនោះទេ។សកម្មភាពគម្រោងដែលមានសិទ្ធិចូលរួមមានជាអាទិ៍គម្រោងយុត្តិធម៌បរិស្ថានដែលធ្វើឱ្យប្រសើរឡើងនូវគុណភាពខ្យល់គុណភាពទឹកការសម្អាតបរិស្ថានកំណកអាកាសឬការលុបបំបាត់សារធាតុសំណឬអាបស្តូស។

គោលដៅគឺដើម្បីកាត់បន្ថយឧបសគ្គនិងផ្តល់នូវដំណើរការដាក់ពាក្យសុំកាន់តែសាមញ្ញសម្រាប់ការផ្តល់មូលនិធិសហព័ន្ធរួមមានទម្រង់បែបបទតិចជាងមុនលក្ខខណ្ឌតម្រូវថវិកាតិចជាងមុនបរិយាយគម្រោងកាន់តែសាមញ្ញនិងប្រព័ន្ធជំនួយដែលកាន់តែងាយស្រួលក្នុងការប្រើប្រាស់។Philanthropy Northwest និងទីភ្នាក់ងារជំនួយបច្ចេកទេសផ្សេងទៀតនឹងផ្តល់ជំនួយក្នុងដំណើរការដាក់ពាក្យសុំនិងដំណើរការគ្រប់គ្រងជំនួយ។

កម្មវិធីផ្តល់ជំនួយលើកស្ទួយសហគមន៍ត្រូវបានបង្កើតឡើងដោយរដ្ឋបាលBiden-Harrisដែលជាផ្នែកមួយនៃរបៀបវារៈនៃការវិនិយោគនៅអាមេរិក។តាមរយៈច្បាប់កាត់បន្ថយអតិផរណាដែលជាការវិនិយោគដ៏ធំបំផុតក្នុងសកម្មភាពអាកាសធាតុក្នុងប្រវត្តិសាស្ត្រ។រដ្ឋបាលបានប្តេជ្ញាចំណាយទុន $600លានដុល្លារទូទាំងប្រទេសក្នុង
រយៈពេល
បីឆ្នាំដល់កម្មវិធីផ្តល់ជំនួយ។កម្មវិធីនេះគឺជាផ្នែកមួយនៃបណ្តាញលើកស្ទួយសហគមន៍អន្តរភ្នាក់ងារសហព័ន្ធនិងផ្តល់ឱ្យនូវគំនិតផ្តួចផ្តើមJustice40 របស់រដ្ឋបាលក្រោមបទបញ្ជា 14008 ដែលកំណត់គោលដៅថា40%នៃអត្ថប្រយោជន៍នៃការវិនិយោគរបស់សហព័ន្ធជាក់លាក់ត្រូវធ្លាក់ទៅដល់

សហគមន៍ដែលជួបការលំបាករងការខ្វះខាតដោយខ្វះការវិនិយោគនិងរងបន្ទុកលើសលប់ដោយសារការបំពុល។នៅក្រោមបទបញ្ជា14008ដែលកំណត់គោលដៅថា 40% នៃអត្ថប្រយោជន៍នៃការវិនិយោគសហព័ន្ធជាក់លាក់ធ្លាក់ទៅលើសហគមន៍ដែលជួបការលំបាករងការខ្វះខាតដោយខ្វះការវិនិយោគនិងរងបន្ទុកលើសលប់ដោយសារការបំពុល។

នៅខែធ្នូឆ្នាំ2023អង្គការPhilanthropy Northwestដោយសហការជាមួយបណ្តាញដៃគូក្នុងតំបន់យ៉ាងទូលំទូលាយនៅទូទាំងRegion 10របស់EPAត្រូវបានជ្រើសរើសជាអ្នកផ្តល់ជំនួយRegion 10សម្រាប់កម្មវិធីផ្តល់ជំនួយលើកស្ទួយសហគមន៍។Region 10រួមមានរដ្ឋAlaska, Idaho, Oregon, Washington និង 271 Tribal Nations នៅក្នុងរដ្ឋទាំងនោះ។គោលដៅរបស់Philanthropy Northwestគឺដើម្បីបែងចែកធនធានដល់សហគមន៍ដែលមានប្រវត្តិខ្វះខាតការវិនិយោគដោយប្រើប្រាស់ភាពជាដៃគូដ៏មានឥទ្ធិពលជួយសម្រួលដល់ការផ្តល់ជំនួយដែលមានការចូលរួមនិងរចនាដំណើរការដាក់ពាក្យសុំសាមញ្ញមួយ។ Philanthropy Northwest នឹងត្រូវបែងចែកថវិកា$40លានដល់តំបន់ក្នុងរយៈពេលបីឆ្នាំ។

មានជំនួយបីប្រភេទដែលអ្នកទទួលជំនួយបន្ទាប់បន្សំដែលមានសក្តានុពលអាចដាក់ពាក្យសុំបានៈ

- **ប្រភេទទីមួយ (គម្រោងវាយតម្លៃ) ទឹកប្រាក់រហូតដល់$150,000** *(រយៈពេលគម្រោង1-ឆ្នាំ)៖*ការផ្តល់មូលនិធិគឺផ្តោតលើការប្រមូលព័ត៌មានការវាយតម្លៃនិងការយល់ដឹងអំពីបញ្ហាមុនពេលបង្កើតផែនការ។
- **ប្រភេទទីពីរ (គម្រោងធ្វើផែនការ) ទឹកប្រាក់រហូតដល់$250,000***(រយៈពេលគម្រោង1-ទៅ2-ឆ្នាំ)៖*ជំនួយសម្រាប់អ្នកដែលមានការយល់ដឹងជ្រាលជ្រៅអំពីបញ្ហាបរិស្ថាននិង/ឬសុខភាពសាធារណៈក្នុងតំបន់ហើយត្រៀមខ្លួនជាស្រេចដើម្បីបង្កើតផែនការសហគមន៍ទាំងមូលដើម្បីដោះស្រាយបញ្ហាទាំងនោះ។
- **ប្រភេទទីបី (អភិវឌ្ឍន៍គម្រោង) សម្រាប់រហូតដល់$350,000***(រយៈពេលគម្រោង2-ឆ្នាំ)៖*ជំនួយសម្រាប់អ្នកដែលមានការយល់ដឹងខ្លាំងអំពីបញ្ហាបរិស្ថាននិង/ឬសុខភាពសាធារណៈក្នុងតំបន់រួចហើយបានបង្កើតផែនការសហគមន៍ទាំងមូលដែលដោះស្រាយបញ្ហាទាំងនោះរួចហើយនិង/ឬឥឡូវនេះបានត្រៀមខ្លួនរួចជាស្រេចក្នុងការអភិវឌ្ឍផ្នែកបច្ចេកទេសនៃគម្រោង (ឧ. អនុវត្តគម្រោងជាក់ស្តែង)។

វាក៏នឹងមានចំនួនកំណត់ $75,000នៃមូលនិធិគម្រោងរងក្នុងចំនួនថេរគ្មានការប្រកួតប្រជែងដែលមានសម្រាប់អង្គការតាមសហគមន៍ដែលធនធានរបស់ខ្លួនមានកម្រិតយ៉ាងខ្លាំង។ការផ្តល់មូលនិធិនេះនឹងត្រូវបានផ្តល់អាទិភាពសម្រាប់អង្គការដែលកំពុងកសាងសមត្ថភាពរបស់ខ្លួនក្នុងការគ្រប់គ្រងគម្រោងធំនិងចំនួនមូលនិធិ។

## 2. គោលបំណង

កម្មវិធីផ្តល់ជំនួយលើកស្ទួយសហគមន៍យុត្តិធម៌បរិស្ថានRegion 10នឹងផ្តល់មូលនិធិដល់អង្គការនានាដែលដោះស្រាយផលប៉ះពាល់មិនស្មើភាពនៃបញ្ហាយុត្តិធម៌បរិស្ថាននៅក្នុងសហគមន៍មូលដ្ឋានទូទាំងតំបន់។

កម្មវិធីជំនួយនេះប្តេជ្ញាចែកចាយមូលនិធិរបស់ EPA ដោយសមធម៌ដល់៖

- អង្គការដែលដឹកនាំដោយសហគមន៍និងបម្រើសហគមន៍ដែលជួបការលំបាកខ្វះខាតជាប្រចាំនិងរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយភាពក្រីក្រគតស្រាកស្រាននិង/ឬវិសមភាពឬ
- អង្គការដែលស្ថិតនៅក្នុងសហគមន៍ជនបទនិងដាច់ស្រយាល
- អង្គការដែលដោះស្រាយយុត្តិធម៌បរិស្ថាន៖សហគមន៍ដែលទទួលចំណែកមិនសមាមាត្រនៃផលបរិស្ថានអវិជ្ជមានដែលកើតចេញពីប្រតិបត្តិការពាណិជ្ជកម្មឬការអនុវត្តកម្មវិធី/គោលនយោបាយសាធារណៈ។

Philanthropy Northwest នឹងផ្តល់អាទិភាពដល់គម្រោងដែលផ្តល់អត្ថប្រយោជន៍ដល់សហគមន៍ Justice40
និងមានការចូលរួមដោយផ្ទាល់ពីសហគមន៍និងប្រជាជនដែលរងផលប៉ះពាល់ដោយបញ្ហាយុត្តិធម៌បរិស្ថាន។

*យុត្តិធម៌បរិស្ថាន*មានន័យថាការប្រព្រឹត្តិត្រឹមត្រូវនិងការចូលរួមប្រកបដោយអត្ថន័យរបស់មនុស្សគ្រប់រូបដោយមិនគិតពីប្រាក់ចំណូលពូជសាសន៍ពណ៌សម្បុរប្រភពដើមជាតិសាសន៍ភាពពាក់ព័ន្ធកុលសម្ព័ន្ធឬពិការភាពក្នុងការសម្រេចចិត្តរបស់ភ្នាក់ងារនិងសកម្មភាពសហព័ន្ធផ្សេងៗដែលប៉ះពាល់ដល់សុខភាពមនុស្សនិងបរិស្ថានដូច្នេះមនុស្ស៖

- ត្រូវបានការពារយ៉ាងពេញលេញពីផលប៉ះពាល់សុខភាពមនុស្សនិងបរិស្ថានដែលមិនសមាមាត្រនិងអវិជ្ជមាន (រួមមានហានិភ័យ)
និងគ្រោះថ្នាក់រួមមានផលប៉ះពាល់ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុផលប៉ះពាល់ជារួមនៃបន្ទុកបរិស្ថាននិងបន្ទុកផ្សេងៗនិងឥទ្ធិពលពីអតីតនៃការរើសអើងជាតិសាសន៍ឬរបាំងរចនាសម្ព័ន្ធឬប្រព័ន្ធផ្សេងៗនិង
- មានសិទ្ធិស្មើគ្នាចំពោះបរិយាកាសដែលមានសុខភាពល្អនិរន្តរភាពនិងរឹងមាំក្នុងការរស់នៅលេងធ្វើការរៀនរីកលូតលាស់គោរពបូជានិងចូលរួមក្នុងការអនុវត្តវប្បធម៌និងការចិញ្ចឹមជីវិត។

## 3. សិទ្ធិចូលរួមនិងលក្ខណសម្បត្តិ

ការផ្តល់មូលនិធិនេះគឺបើកចំហសម្រាប់អង្គការដែលមានសិទ្ធិនៅក្នុងតំបន់ជនបទនិងទីក្រុងនៅទូទាំង Region 10របស់EPA ដែលរួមមានរដ្ឋAlaska, Idaho, Oregon, Washingtonនិង271 Tribal Nations ។

<u>អង្គការដែលមាន</u>សិទ្ធិរួមមាន៖

- អង្គការមិនរកប្រាក់ចំណេញអង្គការមិនរកប្រាក់ចំណេញតាមសហគមន៍និងមូលដ្ឋាន
- រដ្ឋាភិបាលកុលសម្ព័ន្ធ (ទាំងទទួលស្គាល់ដោយសហព័ន្ធនិងរដ្ឋ) និងក្រុមកុលសម្ព័ន្ធ
- រដ្ឋាភិបាលក្នុងតំបន់៖ខោនធីទីប្រជុំជនក្រុងទីក្រុង
- គ្រឹះស្ថានឧត្តមសិក្សា
- អង្គការដែលដឹកនាំដោយជនជាតិដើមអាមេរិក/ជនជាតិដើមភាគតិច
- រដ្ឋាភិបាលក្នុងតំបន់៖ខោនធីទីប្រជុំជនក្រុងទីក្រុង
- គ្រឹះស្ថានឧត្តមសិក្សា

<u>អ្នកទទួល</u>ដែលមិនមានសិទ្ធិរួមមាន៖

- បុគ្គល
- អាជីវកម្មរកប្រាក់ចំណេញ
- រដ្ឋាភិបាលរដ្ឋ

- អង្គការណាមួយដែលត្រូវបានព្យួរឈ្មោះឬរារាំងពីមូលនិធិសហព័ន្ធ

ព័ត៌មានដែលត្រូវការសម្រាប់ការចុះឈ្មោះនៅក្នុងផតថលដាក់ពាក្យសុំជំនួយរួមមានការធានាថាគម្រោងដែលអ្នកកំពុងដាក់ពាក្យសុំមិនពាក់ព័ន្ធនឹងសកម្មភាពដែលមិនមានសិទ្ធិទាំងនេះ៖

- ការបញ្ចុះបញ្ចូលខាងគោលនយោបាយ
- ជំបូន្មានសេវាកម្មឬតំណាងផ្នែកច្បាប់
- សកម្មភាពសាសនាដូចជាការថ្វាយបង្គំការអធិស្ឋានការផ្សព្វផ្សាយឬការណែនាំអំពីសាសនា

**ចំនួនអតិបរមានៃមូលនិធិគម្រោងក្នុងមួយស្ថាប័ន**

ដើម្បីធានាបាននូវការចែកចាយមូលនិធិប្រកបដោយសមធម៌អង្គការមួយត្រូវបានកំណត់ឱ្យទទួលបានជំនួយចំនួនមួយនៅក្នុង Region 10 សម្រាប់រយៈពេលនៃកម្មវិធីលើកស្ទួយសហគមន៍រយៈពេលបីឆ្នាំ។

នៅក្នុងបរិបទនៃការផ្តល់មូលនិធិអង្គការនីមួយៗត្រូវបានកំណត់អត្តសញ្ញាណដោយលេខអត្តសញ្ញាណនិយោជក(EIN) របស់ខ្លួនការចុះឈ្មោះមិនស្វែងរកប្រាក់ចំណេញរបស់រដ្ឋឬការទទួលស្គាល់របស់កុលសម្ព័ន្ធ។ទាំងកុលសម្ព័ន្ធអាមេរិកជនជាតិដើមដែលទទួលស្គាល់ដោយសហព័ន្ធនិងរដ្ឋមានសិទ្ធិដាក់ពាក្យស្នើសុំជំនួយដោយផ្អែកលើស្ថានភាពផ្លូវច្បាប់របស់ពួកគេ។ឧទាហរណ៍អង្គការក្នុងតំបន់ឬថ្នាក់ជាតិដែលមានសាខាច្រើនឬរដ្ឋាភិបាលកុលសម្ព័ន្ធនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញរបស់ខ្លួនអាចមានសិទ្ធិទទួលបានជំនួយលើសពីមួយប្រសិនបើអង្គការនីមួយៗដំណើរការក្រោម EIN ដាច់ដោយឡែកការចុះឈ្មោះរដ្ឋមិនស្វែងរកប្រាក់ចំណេញរបស់រដ្ឋឬការចាត់តាំងរបស់កុលសម្ព័ន្ធ។ការធ្វើដូចនេះធានាថាអង្គភាពផ្សេងគ្នានៅក្នុងបណ្តាញអង្គការទូលំទូលាយឬរចនាសម្ព័ន្ធអភិបាលកិច្ចកុលសម្ព័ន្ធអាចអនុវត្តដោយឯករាជ្យដរាបណាពួកគេបំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់ជំនួយដាច់ដោយឡែក។

អ្នកដាក់ពាក្យអាចប្រើអ្នកឧបត្ថម្ភសារពើពន្ធដោយមានការរឹតបន្តឹងមួយចំនួន។អ្នកឧបត្ថម្ភសារពើពន្ធនីមួយៗអាចទទួលបានមូលនិធិគម្រោងនីមួយៗរហូតដល់ចំនួនប្រាំជាមួយនឹងទឹកប្រាក់អតិបរមាចំនួន $1 លានសម្រាប់មូលនិធិសម្រាប់រយៈពេលនៃកម្មវិធីនេះ។

អ្នកឧបត្ថម្ភសារពើពន្ធត្រូវបានចាត់ទុកថាជាអង្គការអ្នកដាក់ពាក្យហើយទទួលខុសត្រូវចំពោះគ្រប់ទិដ្ឋភាពទាំងអស់នៃជំនួយរួមមានការអនុលោមតាមកិច្ចព្រមព្រៀងផ្តល់ជំនួយការគ្រប់គ្រងហិរញ្ញវត្ថុការរាយការណ៍និងការធានាថាសកម្មភាពដែលទទួលបានមូលនិធិស្របតាមគោលបំណងរបស់ជំនួយ។គម្រោងសារពើពន្ធមិនគួរអនុវត្តដោយគ្មានចំណេះដឹងនិងការយល់ព្រមពីអ្នកឧបត្ថម្ភសារពើពន្ធឡើយ។អង្គការនីមួយៗអាចទទួលបានជំនួយឥតសំណងច្រើនជាងការកំណត់ ប្រសិនបើអង្គការនោះមានឥទ្ធិពលយ៉ាងសំខាន់លើសហគមន៍ មានតម្រូវការបរិស្ថានធ្ងន់ធ្ងរ ឬមានវិធីសាស្ត្រច្នៃប្រឌិតថ្មី។

## 4. លក្ខខណ្ឌតម្រូវនៃការដាក់ពាក្យ

ការដាក់ពាក្យសុំសម្រាប់កម្មវិធីលើកស្ទួយសហគន៍មាននៅទីនេះ។បេក្ខជនទាំងអស់នឹងតម្រូវឱ្យបំពេញពាក្យសុំពេញលេញរួមមានការភ្ជាប់ឯកសារដែលបានស្នើរសុំទាំងអស់ដូចដែលបានស្នើ។

អ្នកដាក់ពាក្យត្រូវតែមានលេខសម្គាល់អង្គភាពពិសេស (UEI) នៅក្នុងប្រព័ន្ធសហព័ន្ធនៃការគ្រប់គ្រងមូលនិធិគម្រោង (Federal System of Award Management, SAM) ដើម្បីមានសិទ្ធិទទួលបានមូលនិធិដែលផ្តល់ជូន។សម្រាប់ស្ថាប័នដែលមិនទាន់មាន UEI សូមជ្រាបថាវាអាចចំណាយពេលច្រើនសប្តាហ៍ដើម្បីចុះឈ្មោះដើម្បីទទួលបានវា។ការចុះឈ្មោះ SAM

មិនត្រូវបានទាមទារនៅពេលដាក់ពាក្យទេប៉ុន្តែប្រសិនបើអ្នកទទួលបានមូលនិធិគម្រោងនោះអង្គភាពរបស់អ្នកនឹងត្រូវការលេខចុះបញ្ជី SAM បច្ចុប្បន្ន/ដែលត្រូវបានអនុម័ត។

បេក្ខជនដែលមិនមានលទ្ធភាពប្រើប្រាស់អ៊ីនធឺណិតគ្រប់គ្រាន់អាចធ្វើការជាមួយមន្ត្រីកម្មវិធី PNW ដើម្បីស្វែងរកដំណោះស្រាយសមរម្យសម្រាប់ការដាក់ពាក្យសុំ។

សម្រាប់ជំនួយបន្ថែមឬការសម្របសម្រួលដើម្បីចូលទៅកាន់ការដាក់ពាក្យស្នើសុំសូមផ្ញើអ៊ីមែលទៅកាន់កម្មវិធីលើកស្ទួយសហគមន៍តាមរយៈthrivingcommunities@philanthropynw.org

ដើម្បីចូលប្រើពាក្យស្នើសុំដំបូងអ្នកត្រូវចុះឈ្មោះជាមួយ Fluxx ដែលជាប្រព័ន្ធជំនួយអនឡាញដែលត្រូវបានរចនាឡើងដើម្បីធ្វើឱ្យដំណើរការនៃការដាក់ពាក្យសុំកាន់តែងាយស្រួលនិងអាចចូលប្រើប្រាស់បានកាន់តែច្រើន។តាមរយៈ Fluxx អ្នកនឹងបញ្ជូនពាក្យសុំហើយប្រសិនបើទទួលបានមូលនិធិគម្រោងដោយជោគជ័យនេះក៏ជាកន្លែងដែលអ្នកនឹងដាក់របាយការណ៍ជំនួយរបស់អ្នកផងដែរ។ព័ត៌មានចូលគណនីរបស់អ្នកមិនត្រូវបានទាញយកដោយ Philanthropy Northwest ទេដូច្នេះសូមរក្សាទុកវាក្នុងកន្លែងសុវត្ថិភាពដូច្នេះអ្នកអាចចូលប្រើប្រព័ន្ធ Fluxx បាន។ប្រសិនបើអ្នកជួបប្រទះបញ្ហាបច្ចេកទេសណាមួយជាមួយការបង្កើតគណនី Fluxx សូមផ្ញើអ៊ីមែលមកយើងតាមរយៈfluxxta@philanthropynw.org។

បន្ទាប់ពីចុះឈ្មោះអ្នកនឹងអាចចូលទៅកាន់ពាក្យសុំជំនួយបាន។នៅពេលចាប់ផ្តើមអ្នកនឹងអាចរក្សាទុកវឌ្ឍនភាពរបស់អ្នកនៅពេលអ្នកធ្វើការបំពេញពាក្យហើយវាមិនទាមទារឱ្យបញ្ចប់ការបំពេញពាក្យក្នុងពេលនេះតែម្តងទេ។

## 5. ថ្លៃចំណាយដែលអាចអនុញ្ញាតនិងមិនអាចអនុញ្ញាត

អ្នកដាក់ពាក្យសុំត្រូវបានណែនាំឱ្យចូលមើលរបៀបបង្កើតកញ្ចប់ថវិកា | US EPAដើម្បីពិនិត្យមើលការបណ្តុះបណ្តាលអនឡាញសម្រាប់ការអភិវឌ្ឍកញ្ចប់ថវិកាជំនួយរបស់ EPA។

| ឧទាហរណ៍នៃថ្លៃចំណាយដែលអាចអនុញ្ញាតបានរួមមាន៖ | | ឧទាហរណ៍នៃការចំណាយដែលមិនអាចអនុញ្ញាតបានរួមមាន*៖ |
|---|---|---|
| • ប្រាក់ខែនិងប្រាក់ឈ្នួល<br>• អត្ថប្រយោជន៍បន្ថែម<br>• ឧបករណ៍/សម្ភារដែលប្រើប្រាស់បាន<br>• សេវាកម្មដែលផ្តល់ដោយអ្នកម៉ៅការឬអ្នកប្រឹក្សាដែលទាក់ទងដោយផ្ទាល់ទៅនឹងគម្រោង (សូមមើលការណែ | | • ភេសជ្ជៈមានជាតិអាល់កុល<br>• ការផាកពិន័យឬការពិន័យ<br>• ការចំណាយទាក់ទងនឹងការបញ្ចុះបញ្ចូលឬសកម្មភាពនយោបាយ<br>• អាហារសន្និសីទភេសជ្ជៈការកម្សាន្តអាហារសម្រន់ការផ្តល់ម្ហូបអាហារ។តម្លៃសម្រាប់អាហារសម្រន់បន្តិចបន្តួចៗនិងអាហារសម្រាប់ការប្រជុំបុគ្គលិករបស់អ្នកទទួលនិងសកម្មភាពប្រចាំថ្ងៃស្រដៀងគ្នានេះមិនត្រូវបានអនុញ្ញាតនៅក្រោមកិច្ចព្រមព្រៀងជំនួយរបស់ EPA ទេ។<br>• អំណោយ |

| | | |
|---|---|---|
| នាំអំពីចំនួនកំណត់អតិបរមានៃអ្នកប្រឹក្សាមិនត្រូវលើសពី $91.95 ក្នុងមួយម៉ោង)។<br>• ឧបករណ៍ចាំបាច់សម្រាប់គម្រោង (បំពេញតាមលក្ខណៈវិនិច្ឆ័យជាក់លាក់)<br>• ថ្លៃចំណាយសម្រាប់ការបណ្តុះបណ្តាលទាក់ទងនឹងគម្រោងនិងសកម្មភាពអប់រំនិង<br>• ថ្លៃចំណាយដោយប្រយោលជាមួយនឹងអត្រាតម្លៃប្រយោលដែលបានអនុម័តឬអត្រាអប្បបរមា 15% | | • ការធ្វើដំណើរកម្រិតព្រីមៀម/កម្រិតអាជីវកម្ម |

*ថ្លៃចំណាយដែលមិនអាចអនុញ្ញាតបានត្រូវបានហាមឃាត់យ៉ាងតឹងរឹងដោយប្រើមូលនិធិ EPA ។អង្គការអាចស្វែងរកមូលនិធិនៅកន្លែងផ្សេងទៀតដើម្បីគាំទ្រតម្រូវការដូចជាអាហារសម្រាប់សន្និសីទនៅខាងក្រៅពាក្យស្នើសុំជំនួយនេះ។

## 6. ទិដ្ឋភាពទូទៅនៃកម្មវិធីនិងប្រភេទនៃមូលនិធិដែលមាន

កម្មវិធីលើកស្ទួយសហគមន៍ផ្តល់ជំនួយសម្រាប់គម្រោងបីប្រភេទ៖

ប្រភេទទី 1៖ការវាយតម្លៃ -
សម្រាប់សហគមន៍ដែលត្រូវការប្រមូលព័ត៌មាននិងស្វែងយល់ពីបញ្ហាយុត្តិធម៌បរិស្ថានមុនពេលពួកគេអាចបង្កើតផែនការនិងចាត់វិធានការដើម្បីគ្រប់គ្រងនិងដោះស្រាយបញ្ហាបានជាស្ថាពរ។

ប្រភេទទី 2៖ការធ្វើផែនការ -
សម្រាប់សហគមន៍ដែលត្រៀមរួចជាស្រេចដើម្បីបង្កើតផែនការសហគមន៍ដើម្បីដោះស្រាយបញ្ហាយុត្តិធម៌បរិស្ថាន។នេះអាចរួមបញ្ចូលការអភិវឌ្ឍភាពជាដៃគូជាមួយអង្គការផ្សេងៗការរៀបចំកិច្ចប្រជុំរៀបចំផែនការនិងការបង្កើតផែនការសកម្មភាពដែលមានគោលដៅគោលបំណងនិងជំហានដែលត្រូវអនុវត្ត។

ប្រភេទទី 3៖ការអភិវឌ្ឍគម្រោង - សម្រាប់សហគមន៍ដែលមានការយល់ដឹងខ្លាំងអំពីបញ្ហាបរិស្ថាននិង/ឬសុខភាពសាធារណៈក្នុងតំបន់រួចហើយបានបង្កើតផែនការសហគមន៍ទាំងមូលសម្រាប់ដោះស្រាយបញ្ហាទាំងនោះហើយ/ឬឥឡូវនេះបានត្រៀមរួចរាល់ក្នុងការអនុវត្តផែនការ។

ប្រភេទជំនួយនីមួយៗមានរយៈពេលផ្ទាល់ខ្លួន។

| ប្រភេទជំនួយ | ចំនួនជំនួយ | រយៈពេលនៃជំនួយ |
|---|---|---|
| ប្រភេទទីមួយ៖គម្រោងវាយតម្លៃ | រហូតដល់$150,000 | រហូតដល់មួយឆ្នាំ (12ខែ) |
| ប្រភេទទីពីរ៖ការធ្វើផែនការ | រហូតដល់$250,000 | 1ឬ2ឆ្នាំ |
| ប្រភេទទីបី៖ការអភិវឌ្ឍគម្រោង | រហូតដល់$350,000 | 2ឆ្នាំ |

ឧទាហរណ៍នៃគម្រោងយុត្តិធម៌បរិស្ថានដែលអាចត្រូវបានផ្តល់មូលនិធិរួមមានជាអាទិ៍៖

- គុណភាពខ្យល់និងជំងឺហឺត
- ការត្រួតពិនិត្យគុណភាពខ្យល់តាមព្រំរបង
- គុណភាពទឹកនិងការប្រមូលគំរូ
- គម្រោងសម្អាតខ្នាតតូច
- ការកែលម្អលទ្ធភាពទទួលបានអាហារដើម្បីកាត់បន្ថយចំនួនម៉ាយល៍យានយន្តលើការធ្វើដំណើរ
- បញ្ហាកំណកអាកាសនិងហេដ្ឋារចនាសម្ព័ន្ធបៃតង
- ការបំពុលដោយសំណនិងអាបស្តូ
- ថ្នាំសម្លាប់សត្វល្អិតនិងសារធាតុពុលផ្សេងៗ
- ផ្ទះដែលល្អសម្រាប់សុខភាពដែលប្រើប្រាស់ថាមពល/ទឹកប្រកបដោយប្រសិទ្ធភាពនិងមិនទទួលរងការបំពុលបរិយាកាសខាងក្នុង
- សកម្មភាពចាក់សំរាមខុសច្បាប់ដូចជាការអប់រំការផ្សព្វផ្សាយនិងការបោសសម្អាតខ្នាតតូច
- ការត្រៀមលក្ខណៈសម្រាប់គ្រាអាសន្ននិងភាពធន់នឹងគ្រោះមហន្តរាយ
- ការបណ្តុះបណ្តាលការងារបរិស្ថានសម្រាប់អាជីពដែលកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់និងការបំពុលបរិយាកាសផ្សេងៗ
- ការបណ្តុះបណ្តាលយុត្តិធម៌បរិស្ថានសម្រាប់យុវជន
- ផ្សេងៗ

គម្រោងដែលស្នើរសុំការស្រាវជ្រាវការប្រមូលគំរូការធ្វើតេស្តការត្រួតពិនិត្យការស៊ើបអង្កេតការប្រើប្រាស់ទិន្នន័យបរិស្ថាននិងសកម្មភាពដែលផ្អែកតាមវិទ្យាសាស្ត្រផ្សេងៗទាមទារឱ្យមានផែនការគម្រោងធានាគុណភាព (QAPP) ដែលអាចទទួលបានការទូទាត់ដោយប្រើជំនួយនេះ។សម្រាប់ព័ត៌មានបន្ថែមអំពីតម្រូវការរបស់ QAPP សូមចូលទៅកាន់គេហទំព័រEPA ឬឬតំណនេះជាមួយនឹងព័ត៌មានបន្ថែមអំពីការប្រមូលទិន្នន័យ។

ប្រសិនបើអ្នកនឹងធ្វើសកម្មភាពស្រាវជ្រាវលើប្រធានបទមនុស្សជាផ្នែកនៃគម្រោងរបស់អ្នកពិធីសារគម្រោងរបស់អ្នកនឹងត្រូវការការអនុម័តដោយក្រុមប្រឹក្សាត្រួតពិនិត្យស្ថាប័ន (IRB) ក៏ដូចជាមន្ត្រីត្រួតពិនិត្យការស្រាវជ្រាវលើប្រធានបទមនុស្ស (HSRRO) នៅ EPA។ដើម្បីស្វែងយល់បន្ថែមថាតើការងាររបស់អ្នកនឹងពាក់ព័ន្ធនឹងការធ្វើការស្រាវជ្រាវលើប្រធានបទមនុស្សឬអត់សូមមើលសំណួរគេសួរញឹកញាប់របស់យើងនៅទីនេះ។

**គម្រោងវាយតម្លៃប្រភេទទី1 - 1 ឆ្នាំរហូតដល់$150,000**

ជំនួយវាយតម្លៃប្រភេទទី 1
គឺសម្រាប់សហគមន៍ដែលត្រូវការប្រមូលព័ត៌មាននិងស្វែងយល់ពីបញ្ហាមុនពេលពួកគេអាចបង្កើតផែនការនិងចាត់វិធានការដើម្បីគ្រប់គ្រងនិងដោះស្រាយបញ្ហាជាស្ថាពរ។

ជំនួយវាយតម្លៃមានសម្រាប់អង្គការនិងអ្នកដាក់ពាក្យសុំដើម្បីជួយពួកគេក្នុងអំឡុងជំហានដំបូងនៃការងាររបស់ពួកគេដើម្បីដោះស្រាយបញ្ហាជាក់លាក់ដែលប៉ះពាល់ដល់ពួកគេនៅក្នុងមូលដ្ឋានដោយធ្វើការវាយតម្លៃអំពីកង្វល់អំពីបរិស្ថាននិងសុខភាពសាធារណៈ។មូលនិធិគម្រោងវាយតម្លៃប្រភេទទី 1 គឺមានតម្លៃរហូតដល់$150,000សម្រាប់រយៈពេលគម្រោងមួយឆ្នាំ។

ខាងក្រោមនេះគឺជាបញ្ជីសកម្មភាពដែលអាចត្រូវបានពិចារណាសម្រាប់មូលនិធិគម្រោងប្រភេទទី1។ឧទាហរណ៍
ទាំងនេះត្រូវបានផ្តល់ជូនសម្រាប់គោលបំណងជាឧទាហរណ៍តែប៉ុណ្ណោះហើយបញ្ជីនេះមិនមានលក្ខណៈទូលំទូលាយទេ៖

- ការស្រាវជ្រាវគុណភាពនិង/ឬបរិមាណ*
- ការប្រមូលគំរូ*
- ការធ្វើតេស្ត*
- ការត្រួតពិនិត្យ*
- ការស៊ើបអង្កេត*
- ការស្ទង់មតិនិងការសិក្សា
- ការអប់រំសាធារណៈ

(* បង្ហាញថាQAPPអាចត្រូវបានទាមទារ)

**ឧទាហរណ៍គម្រោងប្រភេទទី 1**
អង្គការមិនស្វែងរកប្រាក់ចំណេញតូចមួយដែលគាំទ្រគំនិតផ្តួចផ្តើមអធិបតេយ្យភាពចំណីអាហារក្នុងតំបន់ត្រូវបានផ្តល់អំណោយជាដីដែលមានទីតាំងនៅក្នុងសហគមន៍ដែលខ្វះធនធានថវិការធ្ងន់ធ្ងរដើម្បីចាប់ផ្តើមប្រព័ន្ធព្រៃឈើអាហារក្នុងតំបន់។ជាការសោកស្តាយដីឡូត៍នេះត្រូវបានប្រើប្រាស់សម្រាប់ការចោលសំរាមខុសច្បាប់ហើយមានថង់សំរាមនិងកម្ទេចកំទីផ្សេងៗទៀតនៅលើដីនេះ។មូលនិធិនេះនឹងគាំទ្រដល់ការសម្របសម្រួលសម្រាប់អ្នកស្ម័គ្រចិត្តដើម្បីធ្វើការស្ទង់មតិអំពីវិធីសាស្ត្រដើម្បីចងក្រងឯកសារដំណោះស្រាយចាំបាច់និងគ្រោះថ្នាក់សុខភាពដែលអាចកើតមាននៅទីតាំង។គម្រោងប្រភេទនេះទំនងជាត្រូវការផែនការគម្រោងធានាគុណភាព (QAPP)
ពីព្រោះព័ត៌មានបរិស្ថានកំពុងត្រូវបានប្រមូលវាយតម្លៃនិងប្រើប្រាស់។អ្នកផ្តល់ជំនួយនឹងត្រូវធ្វើការជាមួយមន្ត្រីកម្មវិធីរបស់ពួកគេដើម្បីយល់កាន់តែច្បាស់អំពីដំណើរការ QAPP ។

## គម្រោងធ្វើផែនការប្រភេទទី2 – 1-2ឆ្នាំរហូតដល់$250,000

ជំនួយធ្វើផែនការប្រភេទទី 2
គឺសម្រាប់អង្គការដែលបានវាយតម្លៃបញ្ហាយុត្តិធម៌បរិស្ថាននៅក្នុងសហគមន៍របស់ពួកគេហើយត្រៀមខ្លួនជាស្រេចដើម្បីបង្កើតផែនការសហគមន៍ទាំងមូលដើម្បីដោះស្រាយបញ្ហាទាំងនោះ។នេះរួមមានការអភិវឌ្ឍភាពជាដៃគូសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធនិងអង្គការផ្សេងៗដោយរៀបចំកិច្ចប្រជុំរៀបចំផែនការនិងការបង្កើតផែនការសកម្មភាពដែលមានគោលដៅគោលបំណងនិងជំហានដែលត្រូវអនុវត្ត។

សកម្មភាពគម្រោងធ្វើផែនការអាចដោះស្រាយបញ្ហាបរិស្ថានច្រើនជាងមួយ - ឧទាហរណ៍ទាំងគុណភាពខ្យល់និងគុណភាពទឹក។ជំនួយប្រភេទទី 2គឺមានទឹកប្រាក់រហូតដល់$250,000 ក្នុងគម្រោងនីមួយៗសម្រាប់រយៈពេលគម្រោងមួយឬពីរឆ្នាំ។

ខាងក្រោមនេះគឺជាបញ្ជីសកម្មភាពដែលអាចត្រូវបានពិចារណាសម្រាប់មូលនិធិគម្រោងប្រភេទទី2។ទាំងនេះគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ មិនមែនជាបញ្ជីសកម្មភាពពេញនោះទេ៖

- ការធ្វើផែនការ
- ការកសាងភាពជាដៃគូ
- ការផ្សព្វផ្សាយនិងការអប់រំជាសាធារណៈ
- ការសម្របសម្រួលជាមួយសមាជិកសហគមន៍ដើម្បីដោះស្រាយបញ្ហាបរិស្ថាន
- សកម្មភាពបណ្តុះបណ្តាលសម្រាប់អង្គការសហគមន៍និងសមាជិកសហគមន៍
- គម្រោងនិងសកម្មភាពដើម្បីជំរុញការចូលរួមរបស់សហគមន៍ដូចជាការសម្អាតដីទំនេរជាដើម។
- ការទិញនិងកាន់កាប់ដីតូចៗដែលត្រូវការជំនួយតិចជាងពាក់កណ្តាលនៃជំនួយសរុប(រហូតដល់$ 125,000)

ប្រភេទគម្រោងដែលមានលក្ខណៈស្រដៀងគ្នានេះក៏មានសិទ្ធិដូចគ្នាផងដែរ។

**ឧទាហរណ៍គម្រោងប្រភេទទី 2**

សកម្មភាពសហគមន៍នឹងកោះប្រជុំអាជ្ញាធរលំនៅឋានក្នុងតំបន់បរិក្ខារអគ្គិសនីនិងអង្គការដែលផ្តល់សេវាកម្មដល់
សង្គមដើម្បីសម្របសម្រួលលំនៅឋានសុខភាពដែលមានការសហការនិងយុទ្ធនាការផ្គត់ផ្គង់អគ្គិសនីដែលមានអត្ថប្រយោជន៍។យុទ្ធនាការនេះនឹងផ្តល់អត្ថប្រយោជន៍ដល់សហគមន៍ដែលជួបការលំបាកដែលត្រូវផ្លាស់ប្តូរទីលំនៅដោយសារសាងសង់ផ្លូវល្បឿនលឿនកាលពីច្រើនឆ្នាំមុន។គម្រោងនេះផ្តោតលើការបង្កើតផែនការសហគមន៍ទាំងមូលដើម្បីរួមបញ្ចូលការចូលរួមពីភាគីពាក់ព័ន្ធវគ្គបណ្តុះបណ្តាលនិងការអប់រំសាធារណៈ។

## ការអភិវឌ្ឍគម្រោងប្រភេទទី3 - 2ឆ្នាំរហូតដល់$350,000

ជំនួយអភិវឌ្ឍផែនការប្រភេទទី3គឺសម្រាប់សហគមន៍ដែលមានការយល់ដឹងខ្លាំងអំពីបញ្ហាបរិស្ថាននិង/ឬសុខភាពសាធារណៈរបស់ពួកគេរួចហើយបានទទួលលទ្ធផលតាមបែបវិទ្យាសាស្ត្រដែលត្រូវការរួចហើយនិង/ឬបានបញ្ចប់ការវាយតម្លៃបានបង្កើតផែនការសហគមន៍ទាំងមូលដែលដោះស្រាយបញ្ហាទាំងនោះរួចហើយនិង/ឬឥឡូវនេះបានត្រៀមរួចរាល់ក្នុងការអនុវត្តគម្រោងជាក់ស្តែង។

ការបង្កើតឬរក្សាភាពជាដៃគូសំខាន់ៗជាមួយអ្នកពាក់ព័ន្ធក្នុងសហគមន៍គឺជាផ្នែកសំខាន់មួយនៃការអភិវឌ្ឍនិងការអនុវត្តផែនការសហគមន៍ទាំងមូល។ដូច្នេះហើយការបង្កើតភាពជាដៃគូក៏អាចជាផ្នែកមួយនៃគម្រោងអភិវឌ្ឍន៍ផងដែរ។

សកម្មភាពគម្រោងអភិវឌ្ឍន៍អាចដោះស្រាយបញ្ហាបរិស្ថានច្រើនជាងមួយ - ឧទាហរណ៍ទាំងការប៉ះពាល់សារធាតុសំណនិងអាបស្តូស។ជំនួយប្រភេទទី3គឺមានទឹកប្រាក់រហូតដល់$350,000សម្រាប់រយៈពេលគម្រោងពីរឆ្នាំ។

ខាងក្រោមនេះគឺជាបញ្ជីសកម្មភាពដែលអាចត្រូវបានពិចារណាសម្រាប់មូលនិធិគម្រោងប្រភេទទី3។ឧទាហរណ៍ទាំងនេះត្រូវបានផ្តល់ជូនសម្រាប់គោលបំណងជាឧទាហរណ៍តែប៉ុណ្ណោះហើយបញ្ជីនេះមិនមានលក្ខណៈទូលំទូលាយទេ៖

- ប្លង់មេសម្រាប់គម្រោងសាងសង់ឬសម្អាតគ្រោងការណ៍និងការអភិវឌ្ឍបច្ចេកទេស
- ការងារដើម្បីទទួលបានការអនុញ្ញាតសម្រាប់គម្រោងបរិស្ថាន
- ការទិញនិងកាន់កាប់ដីតូចៗដែលត្រូវការជំនួយតិចជាងពាក់កណ្តាលនៃជំនួយសរុប (រហូតដល់$175,000)
- ការអនុវត្តផែនការគម្រោង
- ការផ្សព្វផ្សាយជាសាធារណៈនិងការអប់រំអំពីបញ្ហាយុត្តិធម៌បរិស្ថានរបស់សហគមន៍អ្នក
- ការងារសម្អាតនិងស្តារឡើងវិញ

ប្រភេទគម្រោងដែលមានលក្ខណៈស្រដៀងគ្នានេះក៏មានសិទ្ធិដូចគ្នាផងដែរ។សូមទាក់ទងបុគ្គលិករបស់យើងពាក់ព័ន្ធនឹងសំណួរជាក់លាក់អំពីសិទ្ធិនៃគម្រោងរបស់អ្នក។

**ឧទាហរណ៍គម្រោង**

រដ្ឋាភិបាលកុលសម្ព័ន្ធជនបទបាននឹងកំពុងតាមដានការធ្លាក់ចុះនៃគុណភាពទឹកនៃ Blue River អស់រយៈពេលជាច្រើនឆ្នាំបន្ទាប់ពីការបញ្ឈប់សកម្មភាពរុករករ៉ែនៅតំបន់អាងទន្លេកាលពីជាងមួយទសវត្សរ៍មុន។សមាជិកកុលសម្ព័ន្ធពឹងផ្អែកលើអូរនិងទន្លេសម្រាប់ទឹកផឹកនិងចិញ្ចឹមជីវិតប៉ុន្តែសកម្មភាពទាំងនេះត្រូវបានរឹតត្បិតដោយសារការបំពុលក្នុងទឹកនិងការថយចុះចំនួនត្រី។រដ្ឋាភិបាលកុលសម្ព័ន្ធថ្មីៗនេះបានបញ្ចប់ផែនការធនធានធម្មជាតិដែលបង្ហាញការដោះស្រាយបញ្ហាគុណភាពទឹកនេះជាអាទិភាពខ្ពស់និងរួមបញ្ចូលផែនការគម្រោងធានាគុណភាព (QAPP) ដែលត្រូវបានអនុម័តដោយ EPA រួចហើយតាមរយៈគម្រោងមូលនិធិជំនួយផ្សេងទៀត។ជំនួយនេះនឹងជួយពួកគេឱ្យចាប់ផ្តើមអនុវត្តគំនិតផ្តួចផ្តើមគុណភាពទឹកចំនួនបីដែលបានកំណត់នៅក្នុងដំណើរការធ្វើផែនការ។

## 7. កាលវិភាគកម្មវិធីជំនួយ

សូមមើលកាលវិភាគនៃការត្រួតពិនិត្យមើលនិងកាលវិភាគផ្តល់មូលនិធិសម្រាប់ដំណាក់កាលនីមួយៗនៃការផ្តល់ជំនួយនេះ។ការដាក់ពាក្យសុំជំនួយនឹងត្រូវបានទទួលយកជាបន្តបន្ទាប់សម្រាប់រយៈពេលដែលប្រភេទជំនួយនោះបើក(សម្គាល់ដោយអក្សរ “X” ខាងក្រោម)។ទោះយ៉ាងណាក៏ដោយជុំនីមួយៗមានកាលបរិច្ឆេទកំណត់ដើម្បីជួយសម្រួលដល់ដំណើរការត្រួតពិនិត្យមើលជំនួយប្រកបដោយយុត្តិធម៌និងទាន់ពេលវេលា។សូមចំណាំថាកាលបរិច្ឆេទដាក់ពាក្យសុំគឺអាចផ្លាស់ប្តូរបានហើយអាចត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំក្នុងរយៈពេលបីឆ្នាំនៃការផ្តល់មូលនិធិ។ព័ត៌មានថ្មីៗនឹងមាននៅលើគេហទំព័រ Philanthropy Northwest។

| ជុំ | បើកទទួលពាក្យ | ថ្ងៃផុតកំណត់ដាក់ពាក្យសុំ * | ប្រភេទទី 1 | ប្រភេទទី 2 | ប្រភេទទី 3 | សេចក្តីជូនដំណឹងស្តីពីការជ្រើសរើស |
|---|---|---|---|---|---|---|
| 1 | ថ្ងៃទី 8 ខែតុលាឆ្នាំ 2024 | ថ្ងៃទី 15 ខែធ្នូឆ្នាំ 2024 | | | X | ខែមីនាឆ្នាំ 2025 |
| 2 | ខែមករាឆ្នាំ 2025 | ខែមេសាឆ្នាំ 2025 | X | X | X | ខែមិថុនាឆ្នាំ 2025 |

| | | | | | | |
|---|---|---|---|---|---|---|
| 3 | ខែមីនាឆ្នាំ 2025 | ខែឧសភាឆ្នាំ 2025 | X | X | X | ខែកក្កដាឆ្នាំ 2025 |
| 4 | ខែឧសភាឆ្នាំ 2025 | ខែកក្កដាឆ្នាំ 2025 | X | X | | ខែកញ្ញាឆ្នាំ 2025 |
| 5 | ខែសីហាឆ្នាំ 2025 | ខែតុលាឆ្នាំ 2025 | X | X | | ខែធ្នូឆ្នាំ 2025 |
| 6 | ខែវិច្ឆិកាឆ្នាំ 2025 | ខែកុម្ភៈឆ្នាំ 2026 | X | X | | ខែមេសាឆ្នាំ 2026 |
| 7 | ខែកុម្ភៈឆ្នាំ 2026 | ខែមេសាឆ្នាំ 2026 | X | | | ខែមិថុនាឆ្នាំ 2026 |

* យើងបើកទទួលពាក្យគ្រប់ពេលអំឡុងពេលបើកទទួលពាក្យនៃប្រភេទជំនួយជាក់លាក់ (ដែលសម្គាល់ដោយ "X")។ចំណាំថាក្រឡោន "កាលបរិច្ឆេទដាក់ពាក្យសុំ" ត្រូវគ្នានឹងក្រឡោន "សេចក្តីជូនដំណឹងស្តីពីការជ្រើសរើស"។ឧទាហរណ៍ពាក្យប្រភេទទី 3 ទាំងអស់ដែលទទួលបានត្រឹមថ្ងៃទី15ខែធ្នូឆ្នាំ 2024 នឹងត្រូវបានពិនិត្យសម្រាប់កាលបរិច្ឆេទផ្តល់មូលនិធិគម្រោងនៅខែមីនាឆ្នាំ 2025 ដែលមានសក្តានុពលប្រសិនបើត្រូវបានអនុម័ត។ពាក្យទាំងឡាយណាដែលទទួលបានក្រោយថ្ងៃទី15ខែធ្នូឆ្នាំ2024នឹងត្រូវបានពិនិត្យនៅជុំបន្ទាប់ជាមួយនឹងកាលបរិច្ឆេទផ្តល់មូលនិធិគម្រោងសក្តានុពលខែមិថុនាឆ្នាំ2025។

ប្រសិនបើបានទទួលជំនួយកាលវិភាគគម្រោងចុងក្រោយរបស់អ្នកនឹងត្រូវបានរាយក្នុងកិច្ចព្រមព្រៀងជំនួយហើយនឹងចាប់ផ្តើមភ្លាមៗនៅពេលដែលកិច្ចព្រមព្រៀងផ្តល់ជំនួយត្រូវបានចុះហត្ថលេខា។យើងមិនអាចផ្តល់ពេលវេលាបន្ថែមណាមួយបានទេដូច្នេះសូមរៀបចំផែនការដើម្បីធានាថាជំនួយត្រូវបានចំណាយដល់ចុងបញ្ចប់នៃរយៈពេលជំនួយនេះ។មូលនិធិទាំងអស់ត្រូវតែចំណាយក្នុងរយៈពេលកំណត់នៃកិច្ចព្រមព្រៀងផ្តល់ជំនួយ។

## 8. សំណួរនិងការណែនាំអំពីការដាក់ពាក្យសុំ

សូមមើលគេហទំព័រការលើកស្ទួយសហគមន៍នៃ Philanthropy Northwest សម្រាប់កំណែជា Word ដែលអាចទាញយកបាននៃសំណួរអំពីការដាក់ពាក្យសុំដើម្បីជួយក្នុងការរៀបចំផែនការដាក់ពាក្យសុំសម្រាប់ជំនួយរបស់អ្នក។បុគ្គលិករបស់ Philanthropy Northwest នឹងរៀបចំសិក្ខាសាលាលើបណ្តាញអ៊ីនធឺណិតជាបន្តបន្ទាប់ដើម្បីគាំទ្រដល់ការអភិវឌ្ឍកម្មវិធីរួមជាមួយនឹងរក្សាម៉ោងធ្វើការជាមួយមន្ត្រីកម្មវិធីរបស់យើង។សូមចូលទៅកាន់គេហទំព័រ Philanthropy Northwest សម្រាប់ព័ត៌មានបន្ថែមឬទាក់ទងអាសយដ្ឋានអ៊ីមែលthrivingcommunities@philanthropynw.org។

## 9. ដំណើរការពិនិត្យ

ពាក្យសុំនីមួយៗនឹងត្រូវបានពិនិត្យ និងឲ្យពិន្ទុដោយក្រុមអ្នកសហគមន៍ ដំបូងដោយផ្ទាល់ខ្លួន រួចហើយពិភាក្សាគ្នាជាក្រុម។Philanthropy Northwestនឹងពិនិត្យមើលពិន្ទុពាក្យទាំងអស់ដើម្បីធានាការបែងចែកប្រកបដោយសមភាពក្នុងចំណោមភូមិសាស្ត្រនិងប្រជាសាស្ត្រ។

Philanthropy Northwestនឹងប្រើប្រាស់ដំណើរការត្រួតពិនិត្យរវាងដៃគូដែលផ្តោតលើសហគមន៍ដើម្បីវាយតម្លៃពាក្យដែលនឹងផ្តោតលើការសម្រេចចិត្តនៅក្នុងសហគមន៍Region 10ដើម្បីគោរពអ្នកជំនាញនិងសំឡេងរបស់ពួកគេ។ដំណើរការពិនិត្យនឹងមានបីដំណាក់កាលៈការពិនិត្យ

បឋមការពិនិត្យរបស់ដៃគូសហគមន៍និងដំណើរការសមតុល្យមូលនិធិដើម្បីកំណត់អនុសាសន៍ផ្តល់មូលនិធិ។

ដំណាក់កាលទីមួយនឹងក្លាយជាការត្រួតពិនិត្យបឋមដើម្បីធានាថាពាក្យគឺមកពីអង្គការដែលមានសិទ្ធិហើយគម្រោងទាំងនោះមានសិទ្ធិទទួលបានមូលនិធិនិងថាពាក្យទាំងនោះគឺពេញលេញ។បន្ទាប់ពីឆ្លងកាត់ការត្រួតពិនិត្យបឋមដំណាក់កាលទីពីរគឺការពិនិត្យរបស់ដៃគូសហគមន៍ក្រុមអ្នកត្រួតពិនិត្យដែលជាដៃគូដែលមកពីRegion 10ហើយមិនមានទំនាក់ទំនងជាមួយអង្គការណាមួយដែលដាក់ពាក្យសុំជំនួយសម្រាប់លើកស្ទួយសហគមន៍Region 10នឹងពិនិត្យពាក្យមួយសំណុំតូចរៀងៗខ្លួនហើយដាក់ពិន្ទុឱ្យពួកគេបន្ទាប់មកប្រជុំគ្នាជាក្រុមដើម្បីពិភាក្សាអំពីការឱ្យពិន្ទុរបស់ពួកគេនិងកែតម្រូវប្រសិនបើចាំបាច់។

បន្ទាប់មកពិន្ទុដែលទទួលបានពីក្រុមត្រួតពិនិត្យជាដៃគូនឹងត្រូវបានចងក្រងដោយPhilanthropy Northwestដើម្បីសម្រេចស្វែងរកអ្នកទទួលមូលនិធិគម្រោងសម្រាប់ជុំនៃការផ្តល់មូលនិធិនោះ។អនុសាសន៍មួយចំនួនស្តីពីការផ្តល់មូលនិធិអាចត្រូវបានធ្វើឡើងដោយបុគ្គលិកដើម្បីធានាថាការផ្តល់មូលនិធិត្រូវបានចែកចាយស្មើៗគ្នានៅទូទាំងតំបន់និងទៅកាន់សហគមន៍ Justice40 ។

បុគ្គលិករបស់ Philanthropy Northwest បានធ្វើការជាមួយគណៈកម្មាធិការប្រឹក្សានិងក្រុមការងាររបស់យើងដើម្បីបង្កើតតារាងពិន្ទុពិស្តារមួយដើម្បីពិនិត្យមើលពាក្យសុំជំនួយដោយធានាថាគណៈកម្មាធិការត្រួតពិនិត្យដែលជាដៃគូកំពុងប្រើប្រាស់លក្ខណៈវិនិច្ឆ័យដូចគ្នាដើម្បីដឹកនាំការពិនិត្យរបស់ពួកគេ។

## 10. លក្ខណៈវិនិច្ឆ័យលើការវាយតម្លៃ

ខាងក្រោមនេះគឺជាលក្ខណៈវិនិច្ឆ័យវាយតម្លៃនិងពិន្ទុដែលផ្តល់ជូនសម្រាប់ជំនួយលើកស្ទួយសហគមន៍។

| អាទិភាពនៃការផ្តល់មូលនិធិ | ពិន្ទុ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|
| អត្ថប្រយោជន៍សហគមន៍ ការចូលរួមសហគមន៍និងតំណាងសហគមន៍ | 60 | • កម្មវិធីគាំទ្រដល់សហគមន៍ដែលកំណត់ដោយ Justice40<br>• កម្មវិធីទាក់ទាញការចូលរួមរបស់សមាជិកសហគមន៍ក្នុងការធ្វើផែនការនិងការកំណត់គោលដៅ |
| លទ្ធផលយុត្តិធម៌បរិស្ថាន | 30 | • កម្មវិធីនិយាយអំពីយុត្តិធម៌បរិស្ថាន៖[../../../../../Admin and System Planning/Internal - Admin/Internal team retreat_7.22.24.docx - _msocom_1] សហគមន៍ដែលទទួលចំណែកមិនសមាមាត្រនៃផលវិបាកបរិស្ថានអវិជ្ជមានដែលកើតចេញពីប្រតិបត្តិការពាណិជ្ជកម្មឬការអនុវត្តកម្មវិធី/គោលនយោបាយសាធារណៈ<br>• កម្មវិធីបង្កើតគោលដៅដែលបានកំណត់យ៉ាងច្បាស់និងប្រើប្រាស់ប្រព័ន្ធដើម្បីតាមដានលទ្ធផល។ |

| | | |
|---|---|---|
| ថវិកា * | 10 | • ការចំណាយថវិកាដែលបានស្នើឡើងបង្ហាញភាពសមហេតុផល (អាចអនុញ្ញាតបាន) និងមានយុត្តិកម្មទៅតាមវិសាលភាពកម្មវិធីនិងរយៈពេលគម្រោង |

* **សំណួររៀបរាប់អំពីថវិកា និងថវិកាគឺត្រូវបានទាមទារសម្រាប់តែជំនួយប្រភេទទី 3 ប៉ុណ្ណោះ**

## 11. លក្ខខណ្ឌតម្រូវនៃការរាយការណ៍

### របាយការណ៍ការអនុវត្ត

Philanthropy Northwestមានគោលបំណងបន្ធូរបន្ថយបន្ទុករាយការណ៍សម្រាប់អ្នកទទួលជំនួយ។មន្ត្រីកម្មវិធីនឹងធ្វើការជាមួយអ្នកទទួលជំនួយអំពីរបៀបដែលពួកគេនឹងតាមដាននិងវាស់វែងភាពជោគជ័យរបស់គម្រោងហើយរបាយការណ៍នឹងត្រូវបានដាក់ជូននៅក្នុងប្រព័ន្ធ Fluxx ។

របាយការណ៍នឹងត្រូវបានដាក់ជូនជារៀងរាល់ត្រីមាសហើយនឹងគ្របដណ្តប់លើបច្ចុប្បន្នភាពនិងវឌ្ឍនភាពរបស់គម្រោងភាពជោគជ័យនិងបញ្ហាប្រឈមដែលបានជួបប្រទះលទ្ធផលទិន្នន័យបឋមនិងសេចក្តីថ្លែងការណ៍អំពីសកម្មភាពដែលរំពឹងទុកក្នុងអំឡុងពេលរាយការណ៍ជាបន្តបន្ទាប់រួមមានការពណ៌នាអំពីឧបករណ៍បច្ចេកទេសនិងសម្ភារដែលត្រូវប្រើប្រាស់ឬបានវាយតម្លៃ។បច្ចុប្បន្នភាពអំពីថវិកានិងវឌ្ឍនភាពលើផែនការការងាររួមមានការផ្លាស់ប្តូរណាមួយចំពោះកាលវិភាគដែលរំពឹងទុកនិងការចំណាយនឹងត្រូវបានបញ្ចូលក្នុងរបាយការណ៍ផងដែរ។របាយការណ៍ក៏ត្រូវរួមបញ្ចូលផងដែរនូវការផ្លាស់ប្តូរបុគ្គលិកសំខាន់ៗដែលទាក់ទងនឹងគម្រោងផងដែរ។

## 12. លក្ខខណ្ឌ

សូមមើលប្រការនិងលក្ខខណ្ឌនៃទីភ្នាក់ងារការពារបរិស្ថានដែលអាចអនុវត្តបានសម្រាប់ជំនួយលើកស្ទួយសហគមន៍ Region 10 នៅលើគេហទំព័រ EPAឬជាឯកសារដាច់ដោយឡែកនៅលើគេហទំព័ររបស់យើង។